ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: .០៧៦១/២១...........អអរ

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តក្រចេះ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្ដម ហឿ ស៊ីវយ៉េម ប្រធានក្រុមប្រឹក្សាខេត្តក្រចេះ**
- **លោក សេក ប៊ុនហេង អភិបាលក្រុងក្រចេះ**
- **លោក ឈឹន រិទ្ធ ចៅសង្កាត់អូរឬស្សី ក្រុងក្រចេះ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្ដីផ្ដើម

ខេត្តក្រចេះ ជាខេត្តមួយស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ដែលចែកចេញជា ក្រុង១, ៥ស្រុក ដែលមាន ៥សង្កាត់ ៤២ឃុំ ២៥៨ភូមិ និងមានផ្ទៃដីសរុប ១១.០៩៤ គម² ដែលមានប្រជាជនសរុប ៤១៧.៣២១ នាក់ ស្មើនឹង ៩៤.០៨០ គ្រួសារ ស្រី ២១០.៨៣៧នាក់ ក្នុងនោះប្រជាពលរដ្ឋ ៨១% ជាកសិករ និង១៩% ប្រកបមុខរបរជាអាជីវករ សេវាករ សិប្បកម្ម និងមុខរបរផ្សេងៗទៀតក្រៅពីកសិកម្ម។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ **ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រុមប្រឹក្សាបានរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ១២ដង ក្នុងមួយឆ្នាំ ប្រជាពលរដ្ឋអាចចូលរួមប្រជុំជាសាធារណៈបាន
- បានចាត់វិធានការសមស្រប ដើម្បីដោះស្រាយវិវាទនៅមូលដ្ឋានដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រុមប្រឹក្សាបានធ្វើការត្រួតពិនិត្យ និងដោះស្រាយសំណូមពរ ឬការតវ៉ានានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបានជូនដំណឹងទៅប្រជាពលរដ្ឋវិញ ។
- បានរៀបចំសេចក្តីសម្រេច ស្តីពីការបែងចែកភារកិច្ចជូនដល់សមាជិកក្រុមប្រឹក្សាខេត្ត ជួបប្រាស្រ័យទាក់ទង និងសហការជាមួយក្រុមប្រឹក្សាក្រុង-ស្រុក ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ទីរអង្គភាពជំនាញ និងជាមួយប្រជាពលរដ្ឋក្នុងខេត្ត
- ចំពោះការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាព សាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ច ការងារផ្តល់សេវាសាធារណៈ ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី មានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ព្រមទាំងបានលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង។

❖ **ក្រុងក្រចេះ**

- ការងារកសិកម្ម៖ មានផ្ទៃដីដាំដុះចំនួន ២.៦០៣ហ.ត ក្នុងនោះស្រូវវស្សាចំនួន ១.០៦៤ហ.ត ស្រូវប្រាំង ១.៣៧០ហ.ត និងដំណាំរួមផ្សំចំនួន ១៦៩ហ.ត។
- ការងារសេវាសាធារណៈ៖ បានផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋដែលមកទទួលសេវាលើវិស័យចំនួន ១៤ បានចំនួន សរុប ៧.៦១៧ សេវា។

- ការងារសន្តិសុខ សណ្តាប់ធ្នាប់៖ បានរៀបចំប្រជុំត្រួតពិនិត្យ និងដាក់ផែនការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងក្រុងជាប្រចាំ ព្រមទាំងបានអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដោយធ្វើការផ្សព្វផ្សាយគ្រប់មូលដ្ឋាន និងតាមខ្នងផ្ទះ។
- ការងារទេសចរណ៍៖ ក្រុងក្រចេះ មានតំបន់ទេសចរណ៍ចំនួន ២កន្លែង មានសណ្ឋាគារ និងផ្ទះសំណាក់ ចំនួន ៣៩កន្លែង ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៤៩កន្លែង និងមានភ្ញៀវទេសចរជាតិ ១៦.៨៥០នាក់ និងអន្តរជាតិ ៣៧៦នាក់ ក្នុងឆ្នាំ២០២០។
- ការងារប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ៖ អនុវត្តតាមសារាចរណែនាំ បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល រដ្ឋបាលក្រុងក្រចេះ បានបង្កើតក្រុមការងារ និងធ្វើការចុះផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ-១៩ ដោយជួបផ្ទាល់ ចុះចែក និងបិតខិតប័ណ្ណអំពីអនាម័យលាង សំអាតដៃ ដល់ប្រជាពលរដ្ឋ។

- **សង្កាត់អូរឬស្សី ក្រុងក្រចេះ**

- សង្កាត់រក្សាបានស្ថិរភាពនយោបាយ សន្តិភាព សណ្តាប់ធ្នាប់សង្គមធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត
- បានទប់ស្កាត់ និងគ្រប់គ្រងបានករណីការរីករាលដាលជំងឺកូវីដ-១៩នៅក្នុងសង្កាត់ ដោយអនុវត្ត តាមការណែនាំរបស់រាជរដ្ឋាភិបាល ដោយបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ចុះផ្សព្វផ្សាយពីវិធានការទប់ស្កាត់ ការពារជំងឺកូវីដ-១៩ នៅតាមទីប្រជុំជន និងបណ្តាភូមិនានា
- បានចូលរួមសហការរៀបចំកន្លែងធ្វើចត្តាឡីស័កចំនួន២កន្លែង និងនៅធ្វើចត្តាឡីស័កនៅផ្ទះចំនួន ៣៧នាក់
- ការងារអភិវឌ្ឍន៍៖ បានជួសជុលផ្លូវក្រាលគ្រួសធម្មជាតិចំនួន ៧ខ្សែ, បានជួសជុលផ្លូវក្រាលគ្រួសធម្មជាតិចំនួន ៨ខ្សែ, បានសាងសង់ផ្លូវបេតុងអាមេប្រវែង ២៩៥ម៉ែត្រ និងបានសាងសង់អគាររដ្ឋបាលសាលាសង្កាត់ និងអគារសាលប្រជុំ១ខ្នង។
- រដ្ឋបាលសង្កាត់ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពដើម្បីពង្រឹងនូវសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋ និងអនុវត្តនូវការផ្តល់សេវាសាធារណៈ ក្នុងការបម្រើនូវតម្រូវការរបស់ប្រជាជនបានយ៉ាងល្អប្រសើរ។

## III. ទិសដៅការងារបន្ត

- **ក្រុមប្រឹក្សាខេត្ត**

- បន្តប្រជុំសាមញ្ញ និងវិសាមញ្ញឱ្យបានទៀងទាត់ទៅតាមប្រតិទិនដែលបានអនុម័តរួចហើយ

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ក្នុងការអនុវត្តនូវមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- ជំរុញ និងគាំទ្រលើកកម្ពស់គណនេយ្យភាពសង្គម សំដៅបង្វិតសេវាសាធារណៈឱ្យបានកៀកជិតប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងការអភិវឌ្ឍនៅមូលដ្ឋាន ព្រមទាំងដោះស្រាយនូវរាល់បញ្ហាប្រឈម និងការលំបាកនានារបស់ប្រជាពលរដ្ឋឱ្យបានឆាប់រហ័សទាន់ពេលវេលា
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគខេត្ត
- បន្តគាំទ្រអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងការផ្តល់សេវានៅមូលដ្ឋាន
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

❖ **សង្កាត់អូរឫស្សី ក្រុងក្រចេះ**

- បន្តការខិតខំអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាល និងកម្លាំង ប្រជាការពារជាប្រចាំ ។
- បន្តយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានលឿនរហ័ស និងមិនរើសអើង
- បន្តផ្សព្វផ្សាយពីវិធានការការពារទប់ស្កាត់ជំងឺកូវីដ-១៩
- ផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់នានាពិសេសច្បាប់ចរាចរណ៍ ច្បាប់ភូមិបាលគ្រឿងញៀនជូនប្រជាពលរដ្ឋ និងតាមគ្រឹះស្ថានសិក្សា។
- បន្តចុះរៀបចំសណ្តាប់ធ្នាប់ និងដាក់បង្គោលភ្លើងផ្ទាំងសូឡានៅតាមដងផ្លូវប្រជុំនានា
- បន្តផ្សព្វផ្សាយ និងលើកកម្ពស់ការចូលរួមអនាម័យបរិស្ថាន នៃការគ្រប់គ្រងសំរាមនៅតាមទីប្រជុំជន
- ខិតខំកៀងគរដៃគូរអភិវឌ្ឍន៍អ្នកវិនិយោគ និងសប្បុរសជននានាដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍនៅក្នុងមូលដ្ឋាន។៚

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១